UN-REDD
PROGRAMME

# ការវិភាគលើចំណាយ និង ប្រយោជន៍ នៃការអនុវត្តរេដបូក នៅកម្ពុជា

## កម្មវិធី UN-REDD

របាយការណ៍សិក្ខាសាលា

*សិក្ខាសាលារៀបចំឡើង ជាផ្នែកមួយនៃកម្មវិធីរេដបូកនៅកម្ពុជា*

*ថ្ងៃ អង្គារ ទី ២១ ខែ តុលា ឆ្នាំ ២០១៤ រាជធានីភ្នំពេញ ប្រទេសកម្ពុជា*

រក្សាសិទ្ធិ ដោយ © 2015 United Nations Environment Programme

មជ្ឈមណ្ឌលពិនិត្យតាមដានការងារអភិរក្សពិភពលោកនៃកម្មវិធីបរិស្ថានរបស់សហប្រជាជាតិ (ដែលហៅកាត់ថា UNEP-WCMC) គឺជាមជ្ឈមណ្ឌលឯកទេសអន្តររដ្ឋាភិបាលឈានមុខគេលើការវាយតម្លៃជីវចម្រុះនៃកម្មវិធីបរិស្ថានរបស់សហប្រជាជាតិ (UNEP) ។ មជ្ឈមណ្ឌលនេះបានដំណើរការជាង ៣០ ឆ្នាំមកហើយ ដោយបំពេញការងារខាងការស្រាវជ្រាវវិទ្យាសាស្ត្រផង និងផ្តល់កិច្ចពិគ្រោះយោបល់អំពីគោលនយោបាយសម្រាប់អនុវត្តផង។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយកម្មវិធីរេដបូកជាតិកម្ពុជា និងលេខាធិការដ្ឋានក្រុមការងាររេដបូក ដោយសហការជាមួយនឹងកម្មវិធី UN-REDD។ ដោយបានបង្កើតឡើងនៅឆ្នាំ ២០១១ កម្មវិធី UN-REDD នៅកម្ពុជា ផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវដំណើរការត្រៀមលក្ខណៈសម្រាប់អនុវត្តរេដបូក និងជម្រុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ និងក្របខ័ណ្ឌសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ ការបង្កើនសមត្ថភាពគ្រប់គ្រងរេដបូកនៅថ្នាក់ក្រោមជាតិ និងការរៀបចំប្រព័ន្ធពិនិត្យតាមដាន។ ដោយបានបង្កើតឡើងនៅក្នុងឆ្នាំ ២០១០ ក្រុមការងាររេដបូកកម្ពុជា ជាក្រុមការងារមានសមាសភាពចម្រុះពីស្ថាប័នផ្សេងៗ ហើយមានតួនាទីជាអ្នកសម្របសម្រួលសកម្មភាពពាក់ព័ន្ធនឹងរេដបូកនៅថ្នាក់ជាតិ។ ក្រុមការងារនេះត្រូវបាន សម្របសម្រួលដោយរដ្ឋបាលព្រៃឈើ និងមានសមាជិកចូលរួមមកពីក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។

កម្មវិធី UN-REDD គឺជាគំនិតផ្តួចផ្តើមសហប្រតិបត្តិការរបស់សហប្រជាជាតិ ដើម្បីកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងការរិចរិលព្រៃឈើ (REDD) នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍ។ កម្មវិធីនេះត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ ២០០៨ និងអនុវត្តបន្ថែមពីលើតួនាទី និងជំនាញបច្ចេកទេសរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងកម្មវិធីបរិស្ថានរបស់សហប្រជាជាតិ (UNEP)។ កម្មវិធី UN-REDD ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការគាំទ្រដល់ដំណើរការរេដបូក ដែលដឹកនាំដោយស្ថាប័នថ្នាក់ជាតិ និងជម្រុញឱ្យមានការចូលរួមប្រកបដោយអត្ថន័យ និងផ្អែកទៅតាមព័ត៌មានត្រឹមត្រូវពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងជនជាតិដើមភាគតិច និងសហគមន៍រស់ពឹងអាស្រ័យលើព្រៃឈើទៀតផង នៅក្នុងដំណើរការនៃការអនុវត្តសកម្មភាពរេដបូកទាំងនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

ឯកសារនេះអាចផលិតឡើងវិញបាន សម្រាប់គោលបំណងអប់រំ ឬគោលបំណងមិនរកប្រាក់ចំណេញ ដោយមិនចាំបាច់មានការអនុញ្ញាតពិសេស ដរាបណាមានការថ្លែងអំណរគុណដល់ប្រភពឯកសារនេះ។ ការយករូបភាពនានានៅក្នុងឯកសារនេះទៅប្រើប្រាស់បន្ត ចាំបាច់ត្រូវមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដើម។ ឯកសារនេះមិនអាចប្រើប្រាស់សម្រាប់លក់បន្ត ឬគោលបំណងពាណិជ្ជកម្មផ្សេងទៀត ដោយពុំមានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី UNEP ឡើយ។ ការដាក់ពាក្យសុំការអនុញ្ញាត ជាមួយនឹងការពន្យល់ពីគោលបំណង និងវិសាលភាពនៃការយកឯកសារនេះទៅផលិតឡើងវិញ គួរផ្ញើទៅប្រធាន UNEP-WCMC ដែលមានអាសយដ្ឋាន 219 Huntingdon Road, Cambridge, CB3 0DL, UK។

ខ្លឹមសារនៃរបាយការណ៍នេះមិនឆ្លុះបញ្ចាំងពីពីទស្សនៈ ឬគោលនយោបាយរបស់ UNEP អង្គការ ស្ថាប័នដែលបានចូលរួមចំណែកក្នុងការរៀបចំ ឬកែសម្រួលឯកសារនេះឡើយ។ ការរៀបចំ និងការបង្ហាញក្នុងរបាយការណ៍នេះ មិនបញ្ជាក់ពីគំនិត យោបល់របស់កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ ឬការរួមចំណែករបស់អង្គភាព ឬអ្នកកែសម្រួល ឬអ្នករៀបរៀង ឬពាក់ព័ន្ធទៅនឹងស្ថានភាពផ្លូវច្បាប់នៃប្រទេសណាមួយ ទឹកដី ទីក្រុង ឬអាជ្ញាធរនៃតំបន់ណាមួយ ឬពាក់ព័ន្ធនឹងព្រំដែនជួរមុខ ឬព្រំប្រទល់ ឬការរៀបចំឈ្មោះនៃតំបន់ជួរមុខ ឬព្រំប្រទល់នៃប្រទេសណាមួយឡើយ។ ការលើកឡើង ឬអត្ថន័យដែលមានក្នុងរបាយការណ៍នេះ មិនមែនមានន័យថាបានការទទួលស្គាល់ ឬជាការរួមចំណែកណាមួយពីកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិឡើយ។

ប្រសិនបើអ្នកអានមានបំណងចង់ផ្តល់យោបល់លើឯកសារនេះ សូមមេត្តាទាក់ទងលោក ហុង គឹមហ៊ាន ទីប្រឹក្សាជាតិនៃ លេខាធិការដ្ឋានក្រុមការងាររេដបូក តាមរយៈអ៊ីមែល kimhean-hong@hotmail.com លោកស្រី Charlotte Hicks, UNEP-WCMC តាមរយៈអ៊ីមែល charlotte.hicks@unep-wcmc.org ។

សម្រង់យោងឯកសារនេះ ៖ Hong, K.H., Hicks, C., Väänänen, E. (2015) Costs and Benefits Analysis of REDD+ Implementation in Cambodia: Workshop Report. Phnom Penh, Cambodia, 21 October 2014.Prepared on behalf of the UN-REDD Programme. UNEP World Conservation Monitoring Centre, Cambridge, UK.

**សេចក្តីថ្លែងអំណរគុណ ៖**

សូមថ្លែងអំណរគុណចំពោះសិក្ខាកាមដែលបានចូលរួមក្នុងសិក្ខាសាលា មានដូចជា តំណាងស្ថាប័នរដ្ឋាភិបាល អង្គការអន្តរជាតិ និង អង្គការមិនមែនរដ្ឋាភិបាល ដែលបានផ្តល់យោបល់ និងធាតុចូល។ សូមថ្លែងអំណរគុណចំពោះលេខាធិការដ្ឋានរបស់ក្រុមការងាររេដកម្ពុជា និងទីប្រឹក្សាបច្ចេកទេស ដែលបានពិនិត្យឡើងវិញលើរបាយការណ៍នេះ និងចំពោះបណ្ឌិត Ralph Blaney, UNEP-WCMC, ដែលបានផ្តល់យោបល់ និងដំបូន្មាននានា។

UNEP

WCMC

UNEP ជម្រុញលើកកម្ពស់ការ គិតគូរពីបរិស្ថាននៅក្នុងអនុវត្ត ការងាររបស់ខ្លួននៅទូទាំង សកលលោក និងនៅក្នុង សកម្មភាពផ្ទាល់របស់ខ្លួន។ ការបោះពុម្ពដោយប្រើប្រាស់ក្រដាសដែលផលិតចេញពីព្រៃដែលមាននិរន្តរភាពផ្នែកបរិស្ថាន និងក្រដាសដែលប្រើ ឡើងវិញត្រូវបានលើកទឹកចិត្ត។

## សេចក្តីសង្ខេបរួម

សិក្ខាសាលាស្តីពី "ការវិភាគលើចំណាយ និងប្រយោជន៍នៃការអនុវត្តផេដបូកនៅកម្ពុជា" ត្រូវបានរៀបចំឡើង នៅ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងជាផ្នែកមួយនៃ គម្រោង ដែលផ្តល់ការគាំទ្រដល់ការអនុវត្តកម្មវិធី UN-REDD នៅក្នុងប្រទេសកម្ពុជា តាមរយៈការជួយរៀបចំ និងសាក ល្បងវិភាគលើចំណាយ-ប្រយោជន៍ដែលបានពីផេដបូក និងការវិភាគ spatial analyses ដើម្បីផ្តល់ជាព័ត៌មាន សម្រាប់ ការរៀបចំផែនការផេដបូក។

សិក្ខាសាលានេះមានការចូលរួមពីសិក្ខាកាមជាង ៣០ នាក់ មកពីស្ថាប័នរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការ មិនមែនរដ្ឋាភិបាល ដែលត្រៀមលក្ខណៈក្នុងការអនុវត្តផេដបូកនៅកម្ពុជា។ អ្នកចូលរួមក្នុងសិក្ខាសាលាបានធ្វើការពិនិត្យលើសមាសភាគនានានៃឧបករណ៍តារាង (spreadsheet) បង្ហាញពីចំណាយ-ប្រយោជន៍ ដែលរៀបចំឡើង ដើម្បីជួយឱ្យពួកគេធ្វើការស្វែងយល់ពីចំណាយ និងប្រយោជន៍នៃការអនុវត្តផេដបូកនៅកម្ពុជា។ ឧបករណ៍តារាងនេះធ្វើការពិចារណាលើចំណាយឱកាស ចំណាយសម្រាប់អនុវត្ត និងចំណាយប្រតិបត្តិការនៃជម្រើសនានារបស់ផេដបូក ក៏ដូចជាប្រយោជន៍នានា ដែលផេដបូកអាចផ្តល់ឱ្យ។

តាមរយៈការពិភាក្សាតាមក្រុម អ្នកចូលរួមក្នុងសិក្ខាសាលាបានផ្តល់អនុសាសន៍ជាច្រើន សម្រាប់ធ្វើការកែសម្រួលតារាងនេះ និងបានលើកឡើងពីការលំបាកមួយចំនួន ដូចជា ការបម្លែងចំណាយ និងប្រយោជន៍ទាំងនេះជាតម្លៃក្នុងមួយហិកតា។ អនុសាសន៍សំខាន់ៗ ដែលបានលើកឡើងសម្រាប់ធ្វើការកែសម្រួលតារាងមានដូចខាងក្រោម ៖

- គួរមានការប្រមូលទិន្នន័យបន្ថែមទៀតអំពីកិច្ចការដាក់លាក់ និងចំណាយនានាពីស្ថាប័នពាក់ព័ន្ធឱ្យ បានច្រើន តាមដែលអាចធ្វើបាន (ដើម្បីធ្វើការបញ្ជាក់ផ្ទៀងផ្ទាត់)
- ចំណាយ ពាក់ព័ន្ធជាមួយនឹងកិច្ចការដាក់លាក់ គួរតែមានលក្ខណៈស៊ីជម្រៅជាងនេះ
- គួរមានការធ្វើបច្ចុប្បន្នភាពឯកសាយោង និងទិន្នន័យនៅក្នុងតារាង
- ចំណាយសម្រាប់កិច្ចការដាក់លាក់មួយចំនួនអាចគណនាក្នុងមួយហិកតា ខណៈពេលដែលចំណាយសម្រាប់កិច្ចការផ្សេងទៀតមិនអាចគណនាបែបនេះបាន
- ការគណនាចំណាយនានា គួរធ្វើការពិចារណាលើរចនាសម្ព័ន្ធ/លក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រង
- គួរមានការបញ្ជាក់/កំណត់ពីវិធីសាស្ត្រសម្រាប់គណនាឱ្យបានកាន់តែច្បាស់បន្ថែមទៀត

ជាទូទៅ អ្នកចូលរួមចាត់ទុកតារាងនេះថាជាធនធានមួយដ៏មានតម្លៃ។ សេចក្តីព្រាងចុងក្រោយនៃតារាងនេះនឹង ត្រូវធ្វើការត្រួតពិនិត្យឡើងវិញបន្ថែមទៀត នៅត្រីមាសទីមួយ ឆ្នាំ ២០១៥។

## ១. សេចក្តីផ្តើម

សិក្ខាសាលាស្តីពី "ការវិភាគលើចំណាយ និងប្រយោជន៍នៃការអនុវត្តផែនការផងបូកនៅកម្ពុជា" ត្រូវបានរៀបចំឡើង នៅ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ សិក្ខាសាលានេះត្រូវបានរៀបចំឡើង ក្រោមអធិបតី ភាពរបស់ឯកឧត្តមបណ្ឌិត ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ និងជានាយកកម្មវិធីរេដបូកកម្ពុជា ក្រោមការសម្រប សម្រួលរបស់លោក ឃុន វឌ្ឍនា ប្រធានលេខាធិការដ្ឋានរបស់ក្រុមការងាររេដបូកកម្ពុជា (RTS), Charlotte Hicks (មកពី UNEP-WCMC) និងលោក ហុង គីមហ៊ានទីប្រឹក្សាថ្នាក់ជាតិ។ អ្នកចូលរួមចំនួន ៣២ នាក់ (ស្រី ៦ នាក់ មិនរាប់ បញ្ចូលអ្នកសម្របសម្រួល) បានចូលរួមក្នុងសិក្ខាសាលានេះ (សូមមើលឧបសម្ព័ន្ធទី ១ – បញ្ជីឈ្មោះអ្នកចូលរួម)។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងជាផ្នែកមួយនៃគម្រោងដើម្បីផ្តល់ការគាំទ្រដល់ការអនុវត្តកម្មវិធី UN-REDD នៅក្នុងប្រទេសកម្ពុជា តាមរយៈការជួយរៀបចំ និងសាកល្បងការវិភាគលើចំណាយ–ប្រយោជន៍ដែលបានពីរេដបូក និង ការវិភាគ spatial analyses ដើម្បីផ្តល់ជាព័ត៌មានសម្រាប់ការរៀបចំផែនការរេដបូក។ គម្រោងនេះរួមមាន ការបង្ហាញពីតម្លៃរបស់ព្រៃឈើ ក្រោមរបបគ្រប់គ្រងផ្សេងៗគ្នា រួមជាមួយនឹងការប៉ាន់ប្រមាណពីចំណាយសម្រាប់អនុវត្តជម្រើសរេដបូកផ្សេងៗគ្នា ធៀបជាមួយនឹងជម្រើសនៃការប្រើប្រាស់ដីធ្លីផ្សេងទៀត។ ព័ត៌មាននេះនឹងត្រូវយកទៅប្រើប្រាស់ ដើម្បីរៀបចំសាកល្បងឧបករណ៍វិភាគចំណាយ និងប្រយោជន៍របស់រេដបូក ដោយប្រើប្រាស់បច្ចេកទេស GIS spatial analyses សម្រាប់ប្រទេសកម្ពុជា។

ក្នុងសិក្ខាសាលា សិក្ខាកាមបានធ្វើការពិនិត្យលើសមាសភាគនានានៃតារាង ដែលបង្ហាញពីចំណាយ–ប្រយោជន៍ ដែលរៀបចំឡើងដើម្បីជួយឱ្យពួកគេធ្វើការស្វែងយល់ពីចំណាយ និងប្រយោជន៍នៃការអនុវត្តរេដបូកនៅកម្ពុជា។ ឧបករណ៍នេះធ្វើការពិចារណាលើចំណាយឱកាស ចំណាយសម្រាប់អនុវត្ត និងចំណាយប្រតិបត្តិការនៃជម្រើសនានារបស់រេដបូក ក៏ដូចជាប្រយោជន៍នានា ដែលរេដបូកអាចផ្តល់ឱ្យបាន (សូមមើលប្រអប់ទី ១ ខាងក្រោម សម្រាប់ព័ត៌មាន លំអិតបន្ថែម)។ ទិន្នន័យ នៅក្នុងឧបករណ៍នេះ ត្រូវបានប្រមូលពីប្រភពដែលមាន និងត្រូវបានសម្រិតសម្រាំងឱ្យស្របតាម កាលៈទេសៈ នៅក្នុងប្រទេសកម្ពុជា។ យុទ្ធសាស្ត្រជាក់លាក់ ដែលត្រូវបានយកមកពិចារណានៅក្នុងឧបករណ៍នេះ គិតត្រឹមពេលនេះ រួមមាន ការគ្រប់គ្រងព្រៃឈើតាមសហគមន៍ប្រកបដោយនិរន្តរភាព ការគ្រប់គ្រងតំបន់ការពារ ការស្តារព្រៃឈើ និងការដាំព្រៃឈើឡើងវិញ និងការគ្រប់គ្រងព្រៃប្រកបដោយនិរន្តរភាព។

នៅក្នុងសិក្ខាសាលានេះ មានការធ្វើបទបង្ហាញពីវឌ្ឍនភាព ដែលនាំឲ្យសម្រេចបានឧបករណ៍នេះ។ បន្ទាប់មក អ្នកចូលរួមបានលើកឡើងពីអនុសាសន៍សម្រាប់ធ្វើការផ្លាស់ប្តូរ រួមទាំងការកែលំអប្រភពទិន្នន័យពាក់ព័ន្ធនឹងការចំណាយទៀតផង។ ការពិភាក្សានៅក្នុងសិក្ខាសាលានេះក៏បានរំលេចឱ្យឃើញពីការលំបាកជាច្រើនផងដែរ ដូចជា ការ បម្លែងចំណាយ និងប្រយោជន៍នានា ឱ្យក្លាយជាតម្លៃក្នុងមួយហិចតា ដោយកិច្ចការមួយចំនួនអាចងាយស្រួលប្រើប្រាស់សម្រាប់ការគណនាបែបនេះជាងកិច្ចការផ្សេងទៀត។ ជំហានបន្ទាប់ រួមមាន ការកែសម្រួលឧបករណ៍តារាងបង្ហាញពីចំណាយ និងប្រយោជន៍ (cost-benefit spreadsheet tool) ផ្អែកទៅតាមអនុសាសន៍ ដែលទទួលបានពីសិក្ខាសាលានេះ។

## ២. គោលបំណងរបស់សិក្ខាសាលា

១. បង្ហាញពីឧបករណ៍តារាង (spreadsheet tool) សម្រាប់វាយតម្លៃលើចំណាយ និងប្រយោជន៍នៃការអនុវត្ត រេដបូក នៅកម្ពុជា

២. ស្នើសុំព័ត៌មានបន្ថែមដើម្បីកែសម្រួលឧបករណ៍តារាង ជម្រើសនានានៃយុទ្ធសាស្ត្ររេដបូក និងទិន្នន័យបឋម ដែលត្រូវបានយកមកប្រើប្រាស់

៣. បង្កើនការយល់ដឹងអំពីប្រយោជន៍នៃការវិភាគចំណាយ–ប្រយោជន៍ សម្រាប់ការរៀបចំផែនការរេដបូក

**ប្រអប់ទី ១ ៖ តើការអនុវត្តរេដបូកនាំឱ្យមានចំណាយ និងប្រយោជន៍អ្វីខ្លះ និងហេតុអ្វីបានជាចាំបាច់ត្រូវធ្វើការពិចារណាលើចំណាយ និងប្រយោជន៍ទាំងនេះ នៅក្នុងការរៀបចំផែនការរេដបូក?**

មានចំណាយជាច្រើនប្រភេទ ដែលមានពាក់ព័ន្ធទៅនឹងការអនុវត្តសកម្មភាពរេដបូក ដូចជា ៖

- **ចំណាយឱកាស ៖** ចំណូលដែលបានពីជម្រើសផ្សេងទៀតនៃការប្រើប្រាស់ដីធ្លី ប្រសិនបើដីនេះមិនត្រូវបានប្រើប្រាស់សម្រាប់ សកម្មភាពរេដបូក
- **ចំណាយសម្រាប់ការអនុវត្ត ៖** ចំណាយសម្រាប់ការអនុវត្តសកម្មភាពរេដបូក (ដូចជា ការវិនិយោគពីដំបូង ចំណាយប្រចាំឆ្នាំ)
- **ចំណាយប្រតិបត្តិការ ៖** ចំណាយសម្រាប់ចាប់ផ្តើម និងដំណើរការកម្មវិធីរេដបូក (ដូចជា ចំណាយសម្រាប់ការអភិវឌ្ឍ ចំណាយសម្រាប់ដំណើរការរដ្ឋបាល ជាដើម)

រេដបូកក៏មានសក្តានុពល ក្នុងការផ្តល់នូវប្រយោជន៍ជាច្រើនផងដែរ។ ឧទាហរណ៍ រេដបូកអាចជម្រុញឱ្យមានការអភិរក្សជីវចម្រុះ និងធានាបាននូវសេវាប្រព័ន្ធបរិស្ថានពីព្រៃឈើ ដូចជា ការគ្រប់គ្រងទឹក ការបង្ការការច្រោះដី ការផ្តល់នូវអានុផលព្រៃឈើ ក៏ដូចជា ការបង្កើតចំណូលពីការកាត់បន្ថយការបំភាយឧស្ម័ន។

ចំណាយ និងប្រយោជន៍នានា ដែលពាក់ព័ន្ធនឹងរេដបូក មានការប្រែប្រួលពីប្រទេសមួយ ទៅប្រទេសមួយទៀត និងមានកម្រិត ខុសៗគ្នា ទៅតាមស្ថានភាពបរិស្ថាន សេដ្ឋកិច្ច និងសង្គមផ្សេងៗគ្នា។ ប្រសិទ្ធភាពនៃវិធានការដើម្បីកាត់បន្ថយការបាត់បង់ព្រៃឈើ ក៏ មានការប្រែប្រួលខុសៗគ្នាពីតំបន់ទេសភាពមួយ និងតំបន់ទេសភាពមួយទៀតផងដែរ។ មានតំបន់មួយចំនួន ដែលរេដបូកអាចមិនផ្តល់នូវការចំណាយផ្នែកសេដ្ឋកិច្ច បើគិតតាមការទូទាត់សម្រាប់ការកាត់បន្ថយការបំភាយឧស្ម័នក្នុងមួយតោន ប៉ុន្តែអាចមានតំបន់ខ្លះទៀត ដែលសូម្បីតែការទូទាត់ក្នុងកម្រិតមួយដ៏តិចតួចបំផុតក៏អាចធ្វើឱ្យអន្តរាគមន៍រេដបូកមានភាពទាក់ទាញផងដែរ។

ការបង្កើនការយល់ដឹងអំពីចំណាយ និងប្រយោជន៍ ពាក់ព័ន្ធនឹងជម្រើសរេដបូកផ្សេងៗគ្នា ក៏ដូចជារបាយចំណាយ និងប្រយោជន៍ នៅក្នុងតំបន់ទេសភាពមួយ អាចជួយឱ្យគេកំណត់បាននូវជម្រើសជាអាទិភាពនានា និងផ្តល់នូវធាតុចូលយ៉ាងមានតម្លៃដល់ការពិភាក្សាអំពីការចែករំលែកផលប្រយោជន៍។ ការប្រមូលផ្តុំព័ត៌មានអំពីប្រយោជន៍ និងហានិភ័យ ជាមួយនឹងការវាយតម្លៃលើចំណាយនានា អាចជួយឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្ត កំណត់បានពីសកម្មភាពរេដបូកជាមួយនិងការចំណាយប្រកបដោយប្រសិទ្ធភាព ដែលជួយឲ្យសម្រេចបាននូវប្រយោជន៍ខាងបរិស្ថាន និង សង្គម–សេដ្ឋកិច្ច។

## ៣. សង្ខេបប្រធានបទសិក្ខាសាលា

### ៣.១ បទបង្ហាញ

សិក្ខាសាលានេះចាប់ផ្តើម ជាមួយនឹងសុន្ទរកថាបើករបស់គណអធិបតី ឯកឧត្តម បណ្ឌិត ជា សំអាង អនុប្រធាន រដ្ឋបាលព្រៃឈើ និងជានាយកកម្មវិធីរេដបូកជាតិ ដោយបានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះអ្នកចូលរួម នៅក្នុងកិច្ចប្រជុំនេះ។

បទបង្ហាញរបស់លោក យុន វឌ្ឍនា ប្រធានលេខាធិការដ្ឋានរបស់ក្រុមការងាររេដបូក។ នៅក្នុងបទបង្ហាញរបស់ លោកអំពី "វត្ថុបំណងរបស់សិក្ខាសាលា" លោក យុន វឌ្ឍនា បានបរិយាយអំពីវត្ថុបំណងរបស់សិក្ខាសាលានេះ និងបាន បង្ហាញពីរបៀបវារៈរបស់សិក្ខាសាលានេះ។

បទបង្ហាញទី ២ ក្រោមប្រធានបទ "ចំណាយ និងប្រយោជន៍របស់រេដបូក" ត្រូវបានធ្វើឡើងដោយលោក ហុង គឹមហ៊ាន ជាទីប្រឹក្សាជាតិ។ លោក ហុង គឹមហ៊ាន បានបង្ហាញជារួមអំពីចំណាយ និងប្រយោជន៍នានា ពាក់ព័ន្ធជាមួយនឹង ការអនុវត្តរេដបូក (សូមមើលមើលប្រអប់ទី ១) បន្ទាប់មកមានវគ្គសំណួរ និងចម្លើយ។

បន្ទាប់មក លោកស្រី Charlotte Hicks មន្ត្រីកម្មវិធីរបស់ UNEP-WCMC បានធ្វើបទបង្ហាញអំពី "គម្រោង ចំណាយ និងប្រយោជន៍របស់រេដបូក និងការរៀបចំតារាង" ដោយបង្ហាញដល់អ្នកចូលរួមអំពីឧបករណ៍តារាង (spreadsheet tool) ដែលត្រូវបានព្រាងឡើងនេះ និងរំលេចពីព័ត៌មាន ដែលចង់បានត្រឡប់ពីពួកគេ។

សន្ទរកថារបស់ឯកឧត្តម បណ្ឌិត ជា សំអាង និងបទបង្ហាញទាំងនេះ មាននៅក្នុងឧបសម្ព័ន្ធទី ២។



### ៣.២ លទ្ធផលដែលទទួលបានពីវគ្គពិភាក្សា

ដើម្បីប្រមូលបានព័ត៌មាន ដែលមានលក្ខណៈបច្ចេកទេស ពីអ្នកចូលរួមវគ្គពិភាក្សាមួយត្រូវបានរៀបចំឡើង ដោយមានការបែងចែកអ្នកចូលរួមឱ្យធ្វើការងារជាក្រុម។ អ្នកចូលរួមត្រូវបានបែងចែកជា ៦ ក្រុម ហើយក្រុមនីមួយៗត្រូវ បាន ផ្តល់ឱ្យនូវផ្នែកជាក់លាក់ក្នុងឧបករណ៍តារាងចំណាយ–ប្រយោជន៍ ដែលត្រូវបានព្រាងឡើងដើម្បីផ្តោតការយកចិត្តទុកដាក់នៅក្នុងការពិភាក្សារបស់ខ្លួន។

ក្រុមទី ១ គឺជាក្រុមរបស់អ្នករៀបចំគោលនយោបាយ មកពីវិស័យនានាជាច្រើន ហើយត្រូវបានប្រគល់កិច្ចការឱ្យធ្វើការពិចារណាពីកត្តាសំខាន់ៗបំផុត ដែលនាំឱ្យមានការបាត់បង់ព្រៃឈើ ក៏ដូចជាពិភាក្សាពីជម្រើសនានានៅក្នុងយុទ្ធសាស្ត្រមដប្លកជាតិ ដែលត្រូវបានដាក់បញ្ចូលក្នុងតារាងនេះ។ ពួកគេត្រូវបានសាកសួរថាតើមានជម្រើសអ្វីផ្សេងទៀតចេញពីយុទ្ធសាស្ត្រមដប្លកជាតិ ដែលគួរយកមកបញ្ចូលក្នុងតារាងនេះដែរឬទេ។

ក្រុមទី ២ ដែលមានសមាជិកជាអ្នកចូលរួមជាអ្នក ដែលមានដំណេះដឹងពីទិន្នន័យដែលមាន ត្រូវបានស្នើឱ្យធ្វើការពិនិត្យឡើងវិញលើ ចំណាយសម្រាប់ការអនុវត្ត ចំណាយប្រតិបត្តិការ ចំណាយឱកាស និងប្រយោជន៍នានា ដែលមាននៅក្នុងតារាងនេះ។ ក្រុមនេះត្រូវធ្វើការវាយតម្លៃលើសុក្រិតភាពនៃតួលេខនៅក្នុងតារាង កំណត់ពីតួលេខដែលនៅខ្វះចន្លោះ និងលើកជាអនុសាសន៍អំពីប្រភពទិន្នន័យដែលមានផ្សេងទៀត។

ក្រុមទី ៣ ផ្តោតលើការគ្រប់គ្រងព្រៃឈើដោយសហគមន៍ប្រកបដោយនិរន្តរភាព ដែលជាជម្រើសមួយក្នុងចំណោមជម្រើសយុទ្ធសាស្ត្រនានានៅក្នុងឧបករណ៍តារាងនេះ។ ក្រុមនេះបានធ្វើការពិចារណាលើការដាក់បញ្ចូលបន្ថែមអន្តរាគមន៍ និងកិច្ចការជាក់លាក់នៅក្នុងជម្រើស ក៏ដូចជាប្រយោជន៍ពាក់ព័ន្ធនិងចំណាយសម្រាប់អនុវត្តជម្រើសនេះ។

ក្រុមទី ៤ ធ្វើការពិចារណាលើការគ្រប់គ្រងតំបន់ការពារ ដែលជាជម្រើសយុទ្ធសាស្ត្រមួយទៀតនៅក្នុងឧបករណ៍តារាង និងភាពចាំបាច់ដើម្បីធ្វើការកែសម្រួលអន្តរាគមន៍ និងកិច្ចការជាក់លាក់នានា ដែលត្រូវដាក់បញ្ចូលក្នុងទិន្នន័យចំណាយ និងប្រយោជន៍បឋមនៃអន្តរាគមន៍នេះ។

ក្រុមទី ៥ មានភារកិច្ចពិនិត្យលើជម្រើសយុទ្ធសាស្ត្រទី ៣ នៅក្នុងឧបករណ៍តារាង ពោលគឺជម្រើស ដែលពាក់ព័ន្ធ ជាមួយនឹងការស្តារ និងការដាំព្រៃឡើងវិញ និងពិនិត្យលើលទ្ធភាពសម្រាប់ធ្វើការកែសម្រួលអន្តរាគមន៍ ចំណាយ និងទិន្នន័យបឋមអំពីចំណាយ និងប្រយោជន៍នានា។

លទ្ធផល និងអនុសាសន៍ ដែលទទួលបានពីការបែងចែកក្រុមនេះ ត្រូវបានលើកយកមកបង្ហាញទៅតាមប្រធានបទខាងក្រោម៖

### ក) ជម្រើសយុទ្ធសាស្ត្រសម្រាប់មដប្លក

ជាទូទៅ មានការលើកឡើងពីការកែសម្រួលតិចតួចចំពោះជម្រើសយុទ្ធសាស្ត្រ ដែលមាននៅក្នុងឧបករណ៍តារាង នេះ។ សិក្ខាកាមបានផ្តល់យោបល់អំពីចំណុច ពាក់ព័ន្ធជាមួយនឹងការងារជាក់លាក់ និងកត្តាដែលនាំឱ្យមានការផ្លាស់ប្តូរការប្រើប្រាស់ដីធ្លី ៖

- ត្រូវមានការលើកឡើងពីសារៈសំខាន់នៃការដាក់បញ្ចូលហានិភ័យពាក់ព័ន្ធនឹងអន្តរាគមន៍ ឬកិច្ចការជាក់លាក់ នៅក្នុងឧបករណ៍តារាង
- កំណើនសេដ្ឋកិច្ច កំណើនប្រជាជន និងការពង្រីកសកម្មភាពកសិកម្ម ត្រូវបានចាត់ទុកថាជាកត្តាសំខាន់ជាងគេ ដែលនាំឱ្យមានការបាត់បង់ព្រៃឈើ នៅក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយនេះ

### ខ) ចំណាយឱកាស

- កិច្ចការជាក់លាក់មួយចំនួនបន្ថែមទៀតពាក់ព័ន្ធជាមួយនឹងចំណាយឱកាស គួរបន្ថែមចូលទៅក្នុងតារាងនេះ ៖
    - ទិន្នន័យអំពីដូងប្រេង និងស្វាយចន្ទី ពីនាយកដ្ឋានដំណាំឧស្សាហកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
    - ទិន្នន័យស្រូវ ពីនាយកដ្ឋានដំណាំស្រូវ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ស្ថិតិដែលបានពីជំរឿន កសិកម្ម
    - ទិន្នន័យអំពីត្បូង ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម/ក្រសួងរ៉ែ និងថាមពល
- ដំណាំបន្ថែមទៀត ដូចជា ដំឡូងមី ម្រេច និងកាហ្វេ គួរបន្ថែមចូលទៅក្នុងចំណាយឱកាស

- ចំណាយសម្រាប់ការដាំដុះ នៅក្នុងផ្នែកចំណាយឱកាស ហាក់បីដូចជាមានកម្រិតទាបខ្លាំង និងគួរធ្វើបច្ចុប្បន្នភាព បន្ថែមទៅក្នុងចំណាយ សម្រាប់ឆ្នាំ ២០១៤
- ចំណាយសម្រាប់បរិក្ខារ និងបច្ចេកវិទ្យា គួរបញ្ចូលទៅក្នុងចំណាយឱកាស

## គ) ចំណាយសម្រាប់ការអនុវត្ត ៖

### ***គ. ១. ការគ្រប់គ្រងព្រៃឈើដោយសហគមន៍ប្រកបដោយនិរន្តភាព***

- សិក្ខាកាមបានផ្តល់អនុសាសន៍អំពីការបែងចែកកិច្ចការដាក់លាក់សារឡើងវិញ ពាក់ព័ន្ធជាមួយនឹង ជម្រើសយុទ្ធសាស្ត្រនេះ ៖
  - កិច្ចការដាក់លាក់ចាប់ពីការរៀបចំប្រមូលទិន្នន័យ" រហូតដល់ "ការរៀបចំ និងការឯកភាពលើកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ" គួរដាក់ជាប្រភេទអន្តរាគមន៍នៃការបង្កើតសហគមន៍ព្រៃឈើ
  - កិច្ចការដាក់លាក់ចាប់ពី "ការបែងចែកប្លុកនៅលើផែនទី" រហូតដល់ "ការស្នើសុំការឯកភាពលើផែនការគ្រប់គ្រងសហគមន៍ព្រៃ ឈើ (CFMP) ពីខណ្ឌរដ្ឋបាលព្រៃឈើ" គួរដាក់ជាប្រភេទអន្តរាគមន៍នៃ ផែនការគ្រប់គ្រងសហគមន៍ព្រៃឈើវិញ។
- ចំណាយលើកិច្ចការដាក់លាក់ពាក់ព័ន្ធជាមួយនឹងការស្នើសុំការឯកភាពលើផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ (CFMP) ពីខណ្ឌរដ្ឋបាលព្រៃឈើ មានកម្រិតខ្ពស់ពេក។
- ចំណាយលើអន្តរាគមន៍អភិវឌ្ឍន៍អាជីវកម្ម នៅតាមសហគមន៍ព្រៃឈើ ដោយមានការគ្រប់គ្រងផលិតកម្មប្រកប ដោយនិរន្តភាព មានកម្រិតខ្ពស់ពេក។ ចំណាយនេះគួរធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងមន្ត្រីមកពីរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន។
- អន្តរាគមន៍ ក្រោមការបង្កើតថ្នាលតាមសហគមន៍ ព្រៃសហគមន៍ និងការកំណត់ព្រំប្រទល់ មានលក្ខណៈត្រួតគ្នា។
- ចំណាយសម្រាប់ការបណ្តុះបណ្តាល មិនគួរបែងចែកទៅតាមផ្ទៃដីឡើយ ប៉ុន្តែគួរគណនាជាចំនួនដងនៃការ បណ្តុះបណ្តាល។
- ជម្រើសយុទ្ធសាស្ត្រ "ការគ្រប់គ្រងព្រៃឈើតាមសហគមន៍ប្រកបដោយនិរន្តរភាព" គួរបែងចែកប្រភេទឡើងវិញ ជា ៤ អន្តរាគមន៍ផ្សេងៗគ្នា ទៅតាម យុត្តាធិការចំនួន ៣ ផ្សេងៗគ្នា ដែលពាក់ ព័ន្ធជាមួយការគ្រប់គ្រងព្រៃឈើ (សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារ សហគមន៍នេសាទ)។ អន្តរាគមន៍ ទាំង ៤ មានដូចជា ៖
  - ការបង្កើត
  - ការរៀបចំផែនការគ្រប់គ្រង
  - ការអនុវត្ត និងការអភិវឌ្ឍអាជីវកម្ម (កិច្ចការ "ល្បាត" ជាក់លាក់ គួរដាក់បញ្ចូល)
  - ការកសាងសមត្ថភាព និងការបណ្តុះបណ្តាល



### ***គ. ២ ការគ្រប់គ្រងតំបន់ការពារ***

- ការកែសម្រួលអន្តរាគមន៍ និងកិច្ចការដាក់លាក់មួយចំនួន ត្រូវបានលើកឡើង ៖
  - គួរមានការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការការពារជាជាងលើការដាំព្រៃឈើឡើងវិញ ដោយសារតែជាធម្មតា ចំណាយលើការការពារមានកម្រិតទាបជាង
  - កិច្ចការដាក់លាក់ ដូចជា "ការបែងចែកតំបន់សម្រាប់ដាំឈើសម្រាប់ធ្វើឧស "ឡូត៍ឈើ)" គួរបន្ថែមចូល
  - ការបែងចែកតំបន់ (ការកំណត់) ដែលមានសក្តានុពល នៅក្នុងតំបន់ការពារសម្រាប់គ្រប់គ្រង គួរ លើកឡើងនៅក្នុងតារាងនេះ
  - កិច្ចការដាក់លាក់ ដូចជា "ការគាំទ្រដល់ការពិនិត្យតាមដានសាលក្រមតុលាការលើបទល្មើសព្រៃឈើ" គួរ ត្រូវបានលើកឡើង
  - ការចំណាយលើការល្បាតមានកម្រិតទាប (២,៨៨ ដុល្លារ/ហិកតា)។ ចំណាយនេះគួរបង្កើនដល់ ១០-២០ ដុល្លារ ក្នុងមួយហិកតា/ឆ្នាំ ។

- ទិន្នន័យអំពីចំណាយ និងសមាសភាគនានាសម្រាប់រៀបចំផែនការគ្រប់គ្រង អាចរកបានពីតំបន់ការពារជួរភ្នំក្រវាញភាគកណ្តាល (CCPF) និងសម្រាប់គម្រោងនៅសីមា និងឧត្តរមានជ័យ។

### គ. ៣ ការស្តារ និងការដាំព្រៃឡើងវិញ

- ការកែសម្រួលអន្តរាគមន៍ និងកិច្ចការជាក់លាក់មួយចំនួន ត្រូវបានលើកឡើង ៖
  - គួរកែសម្រួលត្រង់កិច្ចការជាក់លាក់ "ការដាំកូនឈើ"។ ជាធម្មតា ត្រូវមានកូនឈើ ១៧០០ ដើម ក្នុងមួយហិកតា ជាមួយនឹងចំណាយ ០,៥ ដុល្លារ ក្នុងមួយដើម (នៅក្នុងករណីដាំដើមឈើឡើងវិញដោយពុំមានលទ្ធភាពដុះឡើងវិញដោយធម្មជាតិ)។
  - ភាពញឹកញាប់នៃ "ការផលិតស្ប៉ត់ទូរទស្សន៍ស្តីពីការដាំព្រៃឡើងវិញ" (កិច្ចការជាក់លាក់មួយ ក្នុងចំណោមកិច្ចការជាក់លាក់នានា នៅក្នុងឯកសារគម្រោងដែលត្រូវបានពិនិត្យសម្រាប់ឧបករណ៍តារាងនេះ) គួរដាក់បញ្ចូលដដែល ប៉ុន្តែកែសម្រួលមក ២ ដង ក្នុងរយៈពេល ៥ ឆ្នាំ ជាជាងរៀងរាល់ឆ្នាំ។
  - ចំណាយ សម្រាប់ការដាំព្រៃឡើងវិញ នៅក្នុងតារាងមានកម្រិតទាបខ្លាំង (៨០០ ដុល្លារ/ហិចតា)។ បច្ចុប្បន្ននេះ ចំណាយសម្រាប់ការដាំព្រៃឡើងវិញ សម្រាប់ពពួកឈើក្នុងស្រុកផ្ទាល់ គឺ ១៤៥០ ដុល្លារ/ហិកតា (ចាប់ពីការបណ្តុះកូនឈើ រហូតដល់ការដាំឈើរួចរាល់តែម្តង)។
  - ចំណាយ សម្រាប់ថែទាំកូនឈើ គួរលើកឡើងនៅក្នុងតារាងនេះ (ក្រោមអន្តរាគមន៍ដាំឈើឡើងវិញ)។ ជាធម្មតា ចំណាយនេះត្រូវបានគណនាយ៉ាងហោចណាស់ សម្រាប់រយៈពេល ៥ ឆ្នាំ ក្រោយពេលដាំរួច។

### គ. ៤ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

- អនុសាសន៍ សម្រាប់អន្តរាគមន៍ និងកិច្ចការជាក់លាក់មួយចំនួន រួមមាន ៖
  - សម្រាប់អន្តរាគមន៍ពាក់ព័ន្ធនឹងបច្ចេកទេរុក្ខវប្បកម្មព្រៃឈើ (silvicultural) គួរបន្ថែមកិច្ចការជាក់លាក់បន្ថែមទៀត ដូចជា ការដាំព្រៃឡើងវិញ និង "ការចិញ្ចឹម (វារីវប្បកម្ម) ក្តាម-បង្គារ រួមគ្នា" ជាដើម
  - អន្តរាគមន៍ចំនួនពីរទៀត គួរបន្ថែមក្រោមជម្រើសយុទ្ធសាស្ត្រនេះ។ ទីមួយ គឺបង្កើនការយល់ដឹងជាសាធារណៈ ដែលក្នុងនោះគួរដាក់បញ្ចូលនូវកិច្ចការជាក់លាក់ជាច្រើន ដូចជា ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ យុទ្ធនាការ ស្លាកសញ្ញា ផ្ទាំងប៉ាណូ។ អន្តរាគមន៍មួយទៀត គឺការគ្រប់គ្រងរួមគ្នា ពោលគឺគួរមានការលើក ឡើងនូវកិច្ចការគ្រប់គ្រងរបស់ស្ថាប័នទាំង ៣ (រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងក្រសួងបរិស្ថាន)
  - សម្រាប់អន្តរាគមន៍កំណត់ព្រំប្រទល់ ការចុះបញ្ជីដីព្រៃ គួរមានបន្ថែមកិច្ចការ "កំណត់ព្រំប្រទល់ ព្រៃកោងកាង" ដែលត្រូវការចំណាយសម្រាប់ប្រមាណជា ៤០០ ??? បង្គោល
  - ចំណាយសម្រាប់ការរៀបចំវិញ្ញាប័នប័ត្របញ្ជាក់លើផល អនុផលព្រៃឈើ អាចរកបានពីក្រសួងពាណិជ្ជកម្ម
- គួរធ្វើបច្ចុប្បន្នភាពសម្រង់យោង (Citations)/ប្រភពទិន្នន័យសម្រាប់តារាងនេះ។ ឯកសារយោងមួយ ចំនួនមានតាំងពីឆ្នាំ ២០០៥ មកម្ល៉េះ មានន័យថា ចំណាយសម្រាប់កិច្ចការជាក់លាក់មួយចំនួន ប្រហែលជាលែង សមស្របសម្រាប់បច្ចុប្បន្នទៀតហើយ
- ចំណាយសម្រាប់សហគមន៍ផ្សេងៗគ្នា ជារឿយៗ មានលក្ខណៈផ្សេងៗគ្នា។ ដោយសារតែចំណាយនានា ប្រែប្រួលអាស្រ័យទៅតាមរចនាសម្ព័ន្ធគ្រប់គ្រង (ឧ. សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារ សហគមន៍នេសាទ) ការគណនានេះគួរផ្តោតលើបែបផែនផ្សេងៗគ្នានៃការគ្រប់គ្រងសហគមន៍។



### ៣.៣ ការពិភាក្សា

ក្រុមនីមួយៗបង្ហាញពីលទ្ធផលនៃការពិនិត្យលើតារាងរបស់ពួកគេ ទៅកាន់សិក្ខាសាលាទាំងមូលវិញ ដែលនាំឱ្យ មានការពិភាក្សាបន្ថែមទៀតអំពីបញ្ហាអាទិភាពនានា។ ផ្អែកទៅតាមលទ្ធផលនៃក្រុមការងារ និងការពិភាក្សា បញ្ហា អាទិភាព ដែលត្រូវផ្តោត នៅក្នុងឧបករណ៍តារាងចំណាយ និងប្រយោជន៍នេះ រួមមាន ដូចខាងក្រោម ៖

- គួរមានការប្រមូលទិន្នន័យបន្ថែមទៀតអំពីកិច្ចការ និងចំណាយនានាពីស្ថាប័នពាក់ព័ន្ធ
- ពិពណ៌នា (កិច្ចការជាក់លាក់) សម្រាប់ចំណាយ គួរមានលក្ខណៈលំអិតជាងនេះ
- គួរមានការធ្វើបច្ចុប្បន្នភាពឯកសារយោងនៅក្នុងតារាង
- គេអាចធ្វើការគណនាចំណាយ សម្រាប់កិច្ចការជាក់លាក់មួយចំនួនក្នុងមួយហិកតា ប៉ុន្តែសម្រាប់កិច្ចការផ្សេង ទៀត គេមិនអាចគណនាបែបនេះបានឡើយ។ ឧទាហរណ៍ ចំណាយសម្រាប់ការបណ្តុះបណ្តាលគួរគណនាទៅ តាមចំនួនដងនៃការបណ្តុះបណ្តាល ពោលគឺមិនត្រូវគណនាក្នុងមួយហិកតាឡើយ
- ការគណនាចំណាយនានា គួរពិចារណាលើរចនាសម្ព័ន្ធគ្រប់គ្រង/លក្ខខណ្ឌផ្សេងៗគ្នា
- គួរមានការបញ្ជាក់បន្ថែម/កំណត់ឱ្យបានច្បាស់លាស់ពីរបៀបគណនា។

ជាទូទៅ តារាងនេះត្រូវបានចាត់ទុកថាជាធនធានមួយដ៏មានតម្លៃ។ យោបល់ និងសំណូមពរនានា ដែលអ្នកចូលរួមបានផ្តល់នៅក្នុងសិក្ខាសាលានេះ នឹងត្រូវចងក្រង ហើយនឹងមានការកែសម្រួលតារាងនេះឡើងវិញ។ សេចក្តីព្រាងចុងក្រោយ នៃឧបករណ៍តារាងនេះនឹងរួចរាល់សម្រាប់ការពិនិត្យឡើងវិញបន្តទៀត នៅត្រីមាសទី ១ ឆ្នាំ ២០១៥។

## ឧបសម្ព័ន្ធ 1: បញ្ជីឈ្មោះអ្នកចូលរួម

| ឈ្មោះ | អង្គការ |
|---|---|
| ឯ ឧ ជា សំអាង | ប្រធានកម្មវិធី REDD+ កម្ពុជា និងជា អនុប្រធានរដ្ឋបាលព្រៃឈើ (FA) |
| លោក យុន វឌ្ឍនា | លេខាធិការនៃលេខាធិការដ្ឋាន REDD+ កម្ពុជា |
| លោក អួន សំអុល | អនុប្រធាន,នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំនិងព្រៃឯកជន (DPP) |
| លោក លឹម ប៊ុណ្ណា | អនុប្រធានការិយាល័យផែនការនិងហិរញ្ញវត្ថុ (DAP) |
| លោក ឡុង រត្តនៈកុមារ | អនុប្រធាននាយកដ្ឋានព្រៃឈើនិងសហគមន៍ព្រៃឈើ (DFC) របស់ FA |
| កញ្ញា ចេស សុភាព | មន្ត្រីអង្គការ JICA (ស្រី) |
| លោក ឈុត ទិត្យសុភា | អនុប្រធានការិយាល័យនៃនាយកដ្ឋានការពារសត្វព្រៃ និងជីវចម្រុះ (FA) |
| លោក លី សុធា | មន្ត្រីនៃរដ្ឋបាលជលផល (FiA) |
| កញ្ញា ទូច ស្រីពៅពីសី | មន្ត្រីរដ្ឋបាលជលផល (FiA) (F) |
| លោក សេង លាង | អនុប្រធាននាយកដ្ឋានអភិរក្សដែននេសាទ (DFC, FiA) |
| លោក គិម សុខា | ប្រធានផ្នែក នៃនាយកដ្ឋានអភិរក្សដែននេសាទ (DFC, FiA) |
| លោក សុខា សុភ័ណ្ឌ | អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធនធានធម្មជាតិ (GDANCP, MoE) |
| លោក សេង រតនៈ | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធនធានធម្មជាតិ (GDANCP/MoE) |
| លោក ថន ចន្ទតារា | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានកសិកម្ម (MAFF) |
| លោក សុខ ធី | អនុប្រធាននាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) |
| លោក ស៊ាប គិមស្រ៊ឹម | មន្ត្រីវិទ្យាស្ថានស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ (FA) |
| លោក អ៊ុំ រក្សមុនី | មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| លោក ម៉ន ប៊ុនថារិទ្ធ | ប្រធានការិយាល័យនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| លោក ស៊ុំ ជាតិ | មន្ត្រីនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| លោក ហេង គន់លាង | ប្រធាននាយកដ្ឋាន នៃក្រសួងរ៉ែ និងថាមពល |
| Alex Diment | Technical Advisor, Wildlife Conservation Society (WCS) |
| លោក ហ៊ត សុគន្ធ | មន្ត្រីគ្រប់គ្រងគម្រោង នៃអង្គការសម្ព័ន្ធសត្វព្រៃ |
| Naomi Matsue | Technical Advisor, FA/JICA (F) |
| Moeko Saito-Jensen | Programme Analyst, UNDP/UN-REDD (F) |
| Anupam Bhatia | Technical Advisor, UNDP/UN-REDD |
| លោក លន់ គិមហ៊ី | មន្ត្រីសម្របសម្រួលកម្មវិធី ប្រចាំនៅលេខាធិការដ្ឋាន REDD+ |
| លោក ប៊ុន រ៉ាស៊ី | មន្ត្រីរដ្ឋបាលជលផលប្រចាំនៅលេខាធិការដ្ឋាន REDD+ |
| កញ្ញា ប៉ាន់ ធីតា | មន្ត្រីគ្រប់គ្រងកម្មវិធី និងហិរញ្ញកិច្ច ប្រចាំនៅលេខាធិការដ្ឋាន REDD+ |
| លោក ឡា ផហា | ទីប្រឹក្សាយោបល់ថ្នាក់ជាតិអង្គការ FAO/UN-REDD |
| លោក តេង ហួត | ជំនួយការគម្រោង FCPF/UNDP |
| លោកស្រី ឌុក សេរីវឌ្ឍនា | មន្ត្រីជំនួយការរដ្ឋបាលប្រចាំនៅលេខាធិការដ្ឋាន REDD+ (F) |

| | |
|---|---|
| លោក ហុង គីមហ៊ាន | ទីប្រឹក្សាយោបល់ថ្នាក់ជាតិ (FA) |
| Charlotte Hicks | Programme Officer, UNEP-WCMC (F) |

**ឧបសម្ព័ន្ធ 2: បទបង្ហាញ**

**2.A.**

សុន្ទរកថា

របស់ឯកឧត្តម ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ

និងជាប្រធានក្រុមការងារកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការ បាត់បង់

និងរេចរឹលព្រៃឈើ កម្ពុជា (ក្រុមការងារ REDD+ កម្ពុជា)

ថ្លែងក្នុងពិធីបើកសិក្ខាសាលា ស្តីអំពី

ការវិភាគលើការចំណាយ និងផលប្រយោជន៍សម្រាប់ការអនុវត្ត REDD+ នៅកម្ពុជា

(ភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤)

-សូមគោរព គណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី ជាទីគោរព

-សូមគោរព លោក លោកស្រី ជាតំណាងតំណាងដៃគូអភិវឌ្ឍន៍ តំណាង UNEP/WCMC និង អង្គការក្រៅរដ្ឋាភិបាលជាទីគោរព

-លោក លោកស្រី ជាមន្ត្រីរាជការ និងសមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងមូលជាទីរាប់អាន

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយរូបខ្ញុំមានឳកាសបានមកជួបឯកឧត្តម លោក លោកស្រី ក្នុងការរៀបចំសិក្ខាសាលាស្តីពី “ **ការវិភាគលើការចំណាយ និងចំណូលសម្រាប់ការអនុវត្ត REDD+ នៅកម្ពុជា** ” ដ៏មានសារៈសំខាន់ នាពេលនេះ។ ក្នុងនាមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ និងក្នុងនាមជាប្រធានក្រុមការងារ REDD+ កម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម លោក លោកស្រី ដែលបានចូលរួមក្នុងអង្គសិក្ខាសាលា ស្តីអំពី **“ការវិភាគលើចំណាយ និងចំណូលសម្រាប់ការអនុវត្ត REDD+ នៅកម្ពុជា ”** នាពេលនេះ។

ខ្ញុំសូមជម្រាបជូនឯកឧត្តម លោក លោកស្រីឲ្យបានជ្រាបថា សិក្ខាសាលាដែលកំពុងរៀបចំឡើងនាពេលនេះ គឺជាឱកាសមួយដ៏វិសេសវិសាលសម្រាប់យើងទាំងអស់គ្នាដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅអំពីសក្តានុពលរបស់ REDD+ និងបញ្ហានានាដែលពាក់ព័ន្ធទៅនឹងការវិភាគលើការចំណាយ និងផលប្រយោជន៍ដែលទទួលបានពីការអនុវត្ត REDD+។ ផលប្រយោជន៍ដែលទទួលបានពី REDD+ មានច្រើន និងស្ថិតក្រោមរូបភាពផ្សេងៗគ្នា ដោយរាប់បញ្ចូលទាំងផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុដែលត្រូវបានទូទាត់ជាមួយនឹងការចំណាយសម្រាប់សកម្មភាពកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងសក្តានុពលនៃផលប្រយោជន៍ដទៃទៀត រួមមាន៖ ការលើកកំពស់ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិ ជាដើម។ ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុរបស់ REDD+ គឺជាការទូទាត់លទ្ធផលដែលទទួលបានពីការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ជាមួយនិងការចំណាយលើសកម្មភាពសម្រាប់ធ្វើឲ្យសម្រេចបាននូវលទ្ធផលនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ ការចំណាយរបស់ REDD+ គឺមានរូបភាព និងទំហំខុសៗគ្នាអាស្រ័យទៅតាមលក្ខខណ្ឌបរិស្ថាន សេដ្ឋកិច្ច និងសង្គម ក៏ដូចជាប្រសិទ្ធិភាពការងារសម្រាប់ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើផងដែរ។

**ឯកឧត្តម លោក លោកស្រីជាទីគោរព**

ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុដែលទទួលបានពី REDD+ មានច្រើនរបៀប និងច្រើនសណ្ឋាន ណាស់ដែលតម្រូវឲ្យយើងទាំងអស់គ្នាមានការបត់បែនប្រកបដោយភាពប៉ិនប្រសប់ ដើម្បីទទួលបាននូវ ផលប្រយោជន៍ជាអតិបរមាពីការងារនេះ។ ក្នុងករណីខ្លះ ការទូទាត់សម្រាប់ REDD+ មិនអាចប្រព្រឹត្ត ទៅបាន តែជាមួយនិងការទូទាត់ដ៏ជាក់លាក់ណាមួយជារៀងរហូតនោះទេ សម្រាប់លទ្ធផលនៃការកាត់ បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។ តែក៏មានករណីខ្លះទៀត លទ្ធផលនៃការកាត់បន្ថយការបំភាយ ឧស្ម័នផ្ទះកញ្ចក់នេះ អាចទូទាត់ក្នុងកម្រិតមួយដ៏សមរម្យផងដែរ។

ការចំណាយសម្រាប់ REDD+ រួមមាន៖ ការចំណាយលើឱកាសរបស់ព្រៃឈើ ការចំណាយ សម្រាប់ការអនុវត្ត REDD+ ការចំណាយសម្រាប់អន្តរកាល ការចំណាយសម្រាប់កិច្ចការរដ្ឋបាល ក៏ដូច ជាការចំណាយសម្រាប់កិច្ចការសង្គមផងដែរ។ការចំណាយលើឱកាសរបស់ព្រៃឈើ គឺជាការ ចំណាយដែលកើតឡើងដោយការបាត់បង់ផលប្រយោជន៍របស់ព្រៃឈើក្រោមយន្តការ REDD+ គឺ មានន័យថា ជាការបាត់បង់ផលប្រយោជន៍ដែលអាចនឹងផ្តល់ឲ្យ ដោយការផ្លាស់ប្តូរការប្រើប្រាស់ដី ជំនួសឲ្យព្រៃឈើ។ ភាពខុសគ្នារវាងផលប្រយោជន៍ដែលផ្តល់ឲ្យដោយព្រៃឈើ និងផលប្រយោជន៍ដែលផ្តល់ ឲ្យដោយការផ្លាស់ប្តូរការប្រើប្រាស់ដី គឺជាការចំណាយលើឱកាសសម្រាប់ជៀសវាងការកាប់បំផ្លាញព្រៃឈើ។

ការចំណាយលើឱកាសនេះគឺខុសគ្នាពីតំបន់មួយទៅតំបន់មួយ អាស្រ័យដោយលក្ខខណ្ឌ ធម្មជាតិនៃព្រៃ ភាពអំណោយផលសម្រាប់វិស័យកសិកម្ម ចម្ងាយផ្លូវពីទីផ្សារ ហើយនិងកត្តាផ្សេងៗ ទៀតជាច្រើន។ តែទោះជាយ៉ាងណាក៏ដោយ ថ្ងៃនេះយើងនឹងពិនិត្យតែលើការចំណាយជាមធ្យម លើឱកាសរបស់ព្រៃឈើតែប៉ុណ្ណោះ។

ការចំណាយពីរផ្សេងទៀតដែលយើងនឹងពិនិត្យក្នុងតារាង spreadsheet ក្នុងថ្ងៃនេះផងដែរ គឺការចំណាយសម្រាប់ការអនុវត្ត REDD+ និងការចំណាយសម្រាប់អន្តរកាលរបស់ REDD+។ ការ ចំណាយសម្រាប់ការអនុវត្ត REDD+ គឺជាការចំណាយដែលពាក់ព័ន្ធនឹងការធ្វើឲ្យមានដំណើរការសកម្មភាព REDD+ នៅទីវាល ដោយរាប់បញ្ចូលទាំង៖ ការបោះបង្គោលព្រំប្រទល់ព្រៃឈើ ការយាមល្បាតការពារព្រៃឈើ ការលើកកំពស់ការយល់ដឹងដល់សហគមន៍មូលដ្ឋាន ការដាំដើមឈើ ការតាមដានលទ្ធផលការអនុវត្ត ការទ្រទ្រង់ជីវភាពដើម្បីជៀសវាងការកាប់បំផ្លាញព្រៃឈើ ជាដើម។ ការចំណាយសម្រាប់ការអនុវត្ត REDD+ នេះ គឺខុសៗគ្នាទៅតាមជម្រើសនៃការអនុវត្ត REDD+។.

ការចំណាយអន្តរកាល គឺការចំណាយសម្រាប់ដំណើរការកម្មវិធី REDD+ នៅកម្ពុជា។ នៅក្នុងគម្រូ នៃតារាង spreadsheet ការចំណាយលើការងាររដ្ឋបាលត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃ ការចំណាយអន្តរកាលនេះ។ ការចំណាយនេះរាប់បញ្ចូលទាំងការផ្ទៀងផ្ទាត់នៅថ្នាក់ជាតិ ការរៀបចំ របាយការណ៍ កិច្ចការរដ្ឋបាលសម្រាប់កម្មវិធី REDD+ រាប់បញ្ចូលទាំងការចំណាយសម្រាប់ការទូទាត់ និងសម្របសម្រួលជាមួយភាគីទិញកាបោនផងដែរ។ ដោយកម្មវិធី REDD+ បច្ចុប្បន្ន ទើបតែជាជំហាន ដំបូងនៅទូទាំងសាកលលោក ដូចនេះ តួលេខដែលគួរឲ្យជឿជាក់បាន មានតិចតួចប៉ុណ្ណោះ សម្រាប់លើកយកមកធ្វើការសន្និដ្ឋានលើការចំណាយនេះ។ ដូចនេះ បទពិសោធន៍ពីគម្រោងសាកល្បង REDD+ នានា និងបទពិសោធន៍ពីការងារបរិស្ថានដទៃទៀតជាច្រើន ត្រូវបានលើកយកមក គិតគូរដើម្បីធ្វើការប៉ាន់ស្មានការចំណាយនៅថ្នាក់ជាតិ។

**ឯកឧត្តម លោក លោកស្រីជាទីគោរព**

សិក្ខាសាលាដែលកំពុងរៀបចំនាពេលនេះគឺជាជំហានដំបូងនៃលទ្ធផលសម្រាប់ការវិភាគលើការចំណាយ និងផលប្រយោជន៍សម្រាប់ការអនុវត្ត REDD+ នៅកម្ពុជា។ នៅជំហានបន្ទាប់ យើងនឹងសិក្សាអំពីការរៀបចំផែនការតាមប្រព័ន្ធ GIS បន្ថែមទៀត ដែលការងារនេះនឹងជួយយើងក្នុងការលើកកំពស់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការរៀបចំផែនការ REDD+ នៅកម្ពុជា។ លទ្ធផលដែលយើងរំពឹងទុកពីអង្គសិក្ខាសាលាក្នុងថ្ងៃនេះ គឺការកែលំអតារាង spreadsheet ដែលបានរៀបចំឡើងដោយផ្អែកលើការកំណត់សកម្មភាពជាអាទិភាព និងការសន្មតប្រកបដោយភាពជាក់លាក់។ ដូចនេះ ខ្ញុំសូមឲ្យយើងទាំងអស់គ្នា មេត្តាចូលរួមឲ្យបានសកម្ម និងផុលផុស ឡើងថែមទៀតដើម្បីពិនិត្យ និងកែសម្រួលតារាង spreadsheet នេះ ឲ្យកាន់តែមានភាពល្អប្រសើរ និងសុក្រិតឡើងថែមទៀត។ បន្ទាប់ពីសិក្ខាសាលានេះទៅ  តារាង spreadsheet នេះនឹងត្រូវបានកែលំអបញ្ចប់ ហើយជំហានបន្ទាប់គឺការរៀបចំធ្វើផែនការតាមប្រព័ន្ធ GIS នឹងត្រូវបានចាប់ផ្តើមបន្ត។

ខ្ញុំមានជំនឿជឿជាក់ថាសិក្ខាសាលាដែលយើងរៀបចំក្នុងថ្ងៃនេះគឺជាវិភាគទានមួយដ៏មានសារៈសំខាន់ក្នុងការបង្កើនការយល់ដឹងដល់យើងទាំងអស់គ្នាអំពីការវិភាគលើការចំណាយ និងផលប្រយោជន៍សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការ REDD+ ហើយបានរួមចំណែកក្នុងការបង្កើនប្រសិទ្ធិភាពនៃការចំណាយ ដើម្បីធ្វើឲ្យមាននិរន្តភាពសម្រាប់កម្មវិធី REDD+ នៅកម្ពុជា។

ទីបញ្ចប់ ខ្ញុំសូមជូនពរគណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី សមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងមូល សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ  និងសូមប្រកាសបើកអង្គសិក្ខាសាលាចាប់ពីពេលនេះតទៅ។

សូមអរគុណ

## 2.B. សេចក្តីសង្ខេបគោលបំណងនៃសិក្ខាសាលា, លោក ឃុន វឌ្ឍនា















## 2.B. ការចំណាយនិងអត្ថប្រយោជន៍របស់រ៉េដបូក, លោក ហុង គឹមហ៊ាន



















UN-REDD PROGRAMME
៣- ការកំណត់បរិមាណចំណាយ
ជំពូកនៃថ្លៃចំណាយ៖
៣.១ ចំណាយឱកាស(O)
៣.២ ចំណាយអន្តរកាល និងស្ថាប័ន(T)
ការពិគ្រោះយោបល់នៅថ្នាក់ជាតិ
កម្រិតយោង
ការវាយតម្លៃលទ្ធភាពអនុវត្ត
ការកសាងផែនការយុទ្ធសាស្ត្រ
៣.៣ ចំណាយអនុវត្ត(I)


UN-REDD PROGRAMME
៣- ការកំណត់បរិមាណចំណាយ
ជំពូកនៃថ្លៃចំណាយ៖
៣.១ ចំណាយឱកាស(O)
៣.២ ចំណាយអន្តរកាល និងស្ថាប័ន(T)
៣.៣ ចំណាយអនុវត្ត(I)
ការពិនិត្យតាមដាន
ការកសាងផែនការប្រើប្រាស់ដី
កិច្ចការពារព្រៃឈើ
ការដាំដើមឈើឡើងវិញ
រដ្ឋបាល


UN-REDD PROGRAMME
៤
ហេតុអ្វីត្រូវគិតហួសពីតម្លៃកាបូន
ពហុប្រយោជន៍បានពីព្រៃឈើ:
ជួយបន្សុទ្ធទឹក: ផ្តល់ជាទឹកស្អាត
អនុផលព្រៃឈើ: បន្លែ ផ្លែឈើ គ្រាប់ សត្វព្រៃ ឃ្មុំ...
ទីកន្លែងទេសចរណ៍ធម្មជាតិ: ប្រភពចំណូល និងការងារ
ជួយការពារការហូរច្រោះ: កាត់បន្ថយកំទេចកំទីកកសំណល់
ជួយកែលំអផលិតកម្មដំណាំ: ទិន្នផលដំណាំកើនឡើង
កែលំអអាកាសធាតុនៅមូលដ្ឋាន: ផ្តល់ម្លប់ និងរបាំងខ្យល់
ឱសថរុក្ខជាតិ: ប្រភពជំនួសក្នុងការប្រើប្រាស់ថ្នាំពេទ្យ
តម្លៃវប្បធម៌ និងជំនឿអរូបិយ: អភិរក្សទីសក្ការៈពិសេសៗ
កែតម្រូវលំហូរទឹក: កាត់បន្ថយការជន់លិចនៅតំបន់ទំនាប
ការប្រមូលយកជីវសរីរាង្គ: ស្លឹក សំបក ជ័រទឹក ផ្សិត
និងផ្សេងៗជាច្រើនបន្ថែមទៀត


UN-REDD PROGRAMME
៥
វិភាគលើការបែងចែក
អ្នកណាជាអ្នកទទួលផលប្រយោជន៍?
អ្នកប្រើប្រាស់ដី
រាជរដ្ឋាភិបាល
អ្នកសេដ្ឋកិច្ច


UN-REDD PROGRAMME
សូមអរគុណ

**2.D.** ការណែនាំស្តីពីគម្រោងបង្កើតគម្រូតារាងចំណាយ និងផលប្រយោជន៍កម្មវិធីរេដបូក, Ms Charlotte Hicks





















| Context | Cost US$ 2014 | Annual cost US$ | Country |
|---|---|---|---|
| STRENGTHENING SUSTAINABLE FOREST MANAGEMENT TO REDUCE GHG EMISSIONS | | | |
| Development and monitoring of carbon payment mechanisms | 100,000 | 25,000 | Cambodia |
| ENHANCING CLIMATE CHANGE RESILIENCE OF RURAL COMMUNITIES LIVING IN PROTECTED AREAS OF CAMBODIA | | | |
| Total project management and monitoring | 325,000 | 65,000 | Cambodia |
| UNDP - Establishing Conservation Areas Landscape Management (CALM) in the Northern Plains | | | |
| Project management and evaluation (administer expenditure and coordinate activities and evaluations) | 693,936 | 99,134 | Cambodia |
| CFI CARBON PROJECT IN OTDAR MEANCHEY PROVINCE, CAMBODIA | | | |
| Total project administration | 135,495 | 135,495 | Cambodia |
| REDD+ costs in Vietnam | | | |
| Monitoring costs | 223,600 | 74,533 | Vietnam |
| Juma reserve - REDD project in Brazil | | | |
| Administration and carbon monitoring (including staff costs and project design document) | 5,912,450 | 131,388 | Brazil |
| Transaction costs of forest carbon projects - review of case studies in Latin America | | | |
| Monitoring, certification and supervision & contract obligations | 3,760,000 | 111,750 | Latin America |
| AVERAGE | | 91,757 | |







| | | | | GOVERNMENT | NATION | LAND USER |
|---|---|---|---|---|---|---|
| REDD+ action | Sited in an area of conservation? | Alternative land use | Include timber values? | Overall gain / loss from REDD+ | Overall gain / loss from REDD+ | Overall gain / loss from REDD+ |
| PA management | Y | Land concession: Rubber | N | $5,244 | $8,359 | $25,055 |
| | | Land concession: Rice | N | $2,133 | $7,630 | $15,899 |
| | | Land concession: Oil palm | N | $446 | $4,045 | $1,062 |
| | | Land concession: Cashew nuts | N | $5,819 | $9,183 | $27,929 |
| | | Luxury timber logging | - | $5,799 | $17,532 | $26,405 |
| | | Standard timber clear-felling | - | $2,107 | $20,091 | $1,503 |
| | | Small-scale use: Rice | N | $2,080 | $1,283 | $3,678 |
| | | Small-scale use: Charcoal | - | $2,188 | $5,394 | $4,238 |




